**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ..៧៤២....សហវ.ប្រក

# ប្រកាស

## ស្តីពី

## វិធាន និងនីតិវិធីសម្រាប់អនុវត្តពន្ធលើប្រាក់ចំណូល និងពន្ធអាករនានាទាក់ទិននឹងសកម្មភាព កាត់ ដេរ និងតម្រឹម របស់គម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់

## ទេសរដ្ឋមន្ត្រី

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៣/០១០ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ ១.- គោលបំណង**

ប្រកាសនេះ មានគោលបំណងលើកទឹកចិត្តដល់ឧស្សាហកម្មក្នុងស្រុក ដើម្បីជំរុញការនាំចេញ និងបង្កើតការងារដល់កម្មករ កម្មការិនី នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ២.- គោលដៅ**

ប្រកាសនេះ មានគោលដៅដាក់ចេញនូវវិធាន និងនីតិវិធីសម្រាប់អនុវត្តពន្ធលើប្រាក់ចំណូល និងពន្ធអាករនានាទាក់ទិននឹងសកម្មភាព កាត់ ដេរ និងតម្រឹម របស់គម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់។

**ប្រការ ៣.- វិសាលភាព**

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ ក្នុងវិស័យកាត់ដេរ វាយនភណ្ឌ ផលិតស្បែកជើង ផលិតកាបូបយួរនិងកាបូបដៃ និងផលិតមួក នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលមានសកម្មភាពផ្គត់ផ្គង់សេវា កាត់ ដេរ និងតម្រឹម តាមកិច្ចសន្យា ដើម្បីធ្វើការនាំចេញ។

ប្រកាសនេះ មិនអនុវត្តចំពោះឧស្សាហកម្មគាំទ្រ ឬអ្នកចុះកិច្ចសន្យាក្នុងស្រុកដែលធ្វើការផ្គត់ផ្គង់ទំនិញឬសេវាសម្រាប់បម្រើឱ្យការនាំចេញរបស់សហគ្រាសកាត់ដេរ វាយនភណ្ឌ ផលិតស្បែកជើង ផលិតកាបូបយួរនិងកាបូបដៃ និងផលិតមួក ដូចមានចែងនៅក្នុងប្រកាសលេខ ៣១១ សហវ.ប្រក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៤។

**ប្រការ ៤.- និយមន័យ**

សម្រាប់គោលដៅនៃប្រកាសនេះ÷

១- ពាក្យ "**កាត់ ដេរ និងតម្រឹម**" ហៅកាត់ថា "**កដត.**" សំដៅដល់ការផ្គត់ផ្គង់សេវា កាត់ ដេរ និងតម្រឹម តាមកិច្ចសន្យាជាមួយម្ចាស់ទំនិញ ដើម្បីនាំចេញជាផលិតផលសម្រេចទៅវិញ។

២- ពាក្យ "**ម្ចាស់ទំនិញ**" សំដៅដល់បុគ្គលអនិវាសនជនដែលចុះកិច្ចសន្យា កាត់ ដេរ និងតម្រឹម ជាមួយសហគ្រាសផ្គត់ផ្គង់សេវា **កដត.**។

៣- ពាក្យ "**វត្ថុធាតុដើម កដត.**" សំដៅលើវត្ថុធាតុដើម និង/ឬសម្ភារផ្គត់ផ្គង់ផ្សេងៗ របស់ម្ចាស់ទំនិញ ដែលសហគ្រាសផ្គត់ផ្គង់សេវា **កដត.** នាំចូលមកក្នុងព្រះរាជាណាចក្រកម្ពុជា សម្រាប់ផ្គត់ផ្គង់សេវា **កដត.** ឱ្យម្ចាស់ទំនិញ ដោយម្ចាស់ទំនិញនៅរក្សាភាពជាម្ចាស់កម្មសិទ្ធិស្របច្បាប់ដដែល។

**ប្រការ ៥.- លក្ខខណ្ឌសម្រាប់ការផ្គត់ផ្គង់សេវា កដត.**

សហគ្រាសដែលផ្គត់ផ្គង់សេវា **កដត.** ត្រូវគោរពតាមលក្ខខណ្ឌដូចខាងក្រោម÷

១- ជូនដំណឹងមកអគ្គនាយកដ្ឋានពន្ធដារ នូវរាល់ប្រតិបត្តិការផ្គត់ផ្គង់សេវា **កដត.** ក្នុងរយៈពេល ៣០ថ្ងៃ បន្ទាប់ពីថ្ងៃចុះកិច្ចសន្យាជាមួយម្ចាស់ទំនិញ ដោយភ្ជាប់មកជាមួយនូវកិច្ចសន្យាផ្គត់ផ្គង់សេវា **កដត.** ដែលមានបញ្ជាក់លម្អិតអំពីទំហំការងារ ថ្លៃឈ្នួលសេវា និងលក្ខខណ្ឌនៃការទូទាត់។

២- កាន់ កត់ត្រា និងថែរក្សា បញ្ជិកាគណនេយ្យ និងព័ត៌មានទាក់ទិននឹងសេវា **កដត.** ស្របតាមស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា និងបទប្បញ្ញត្តិស្តីពីពន្ធដារ។

៣- មានឯកសារគាំទ្រ ដូចមានចែងក្នុងប្រការ៩ នៃប្រកាសនេះ។

**ប្រការ ៦.- ការលើកទឹកចិត្តចំពោះពន្ធលើប្រាក់ចំណូល**

សម្រាប់គោលដៅពន្ធដារ សកម្មភាព **កដត.** ត្រូវបានចាត់ទុកថាជាសកម្មភាពផលិតសម្រាប់នាំចេញដែលត្រូវទទួលបានការលើកទឹកចិត្តពន្ធលើប្រាក់ចំណូល ដូចគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ដែលផលិតសម្រាប់នាំចេញដែរ។

**ប្រការ ៧.- ការតព្វកិច្ចពន្ធលើប្រាក់ចំណូល និងអាករលើតម្លៃបន្ថែមចំពោះសកម្មភាពផ្គត់ផ្គង់សេវា កដត.**

**១- ពន្ធលើប្រាក់ចំណូល**

សហគ្រាសត្រូវកត់ត្រាដោយឡែកនូវចំណូល និងចំណាយ ទាក់ទិននឹងការផ្គត់ផ្គង់សេវា **កដត.** ដូចខាងក្រោម៖

**ក- ប្រាក់ចំណូលជាប់ពន្ធ៖**

- ថ្លៃឈ្នួលសេវា **កដត.** ដោយត្រូវដាក់ជូនរដ្ឋបាលសារពើពន្ធប្រចាំខែនូវតារាងលម្អិតអំពីថ្លៃឈ្នួលសេវាកម្ម កដត. (ដូចមានគំរូភ្ជាប់ក្នុងឧបសម្ព័ន្ធ)
- ចំណូលពីការលក់ផលិតផលខូចខាត ឬលើសនៅក្នុងផលិតកម្ម និង
- ចំណូលផ្សេងៗទៀតក្រៅពីតម្លៃនាំចេញផលិតផល។

**ខ- ចំណាយដែលអាចកាត់កងបាន**

ចំណាយត្រូវអនុវត្ត ស្របតាមច្បាប់និងបទប្បញ្ញត្តិស្តីពីពន្ធលើប្រាក់ចំណូល។

**គ- ប្រាក់រំដោះពន្ធលើប្រាក់ចំណូល និងពន្ធអប្បបរមា**

មូលដ្ឋានសម្រាប់គណនាប្រាក់រំដោះពន្ធលើប្រាក់ចំណូល និងពន្ធអប្បបរមារួមមាន៖

- ថ្លៃឈ្នួលសេវាផ្គត់ផ្គង់ **កដត.**
- ចំណូលពីការលក់ផលិតផលខូចខាតឬលើសនៅក្នុងផលិតកម្ម ឬវត្ថុធាតុដើម **កដត.**។

ចំពោះតម្លៃនៃផលិតផលនាំចេញ មិនត្រូវបានចាត់ទុកជាចំណូលរបស់សហគ្រាសដែលផ្គត់ផ្គង់សេវា **កដត.** សម្រាប់គណនាប្រាក់រំដោះពន្ធលើប្រាក់ចំណូល ឬពន្ធអប្បបរមាទេ។

**២- អាករលើតម្លៃបន្ថែម**

**ក- អាករលើធាតុចេញ៖**

- ការផ្គត់ផ្គង់សេវា **កដត.** សម្រាប់បម្រើសកម្មភាពនាំចេញនៃផលិតផលដែលបានកែច្នៃត្រូវជាប់អាករលើតម្លៃបន្ថែមតាមអត្រា 0%
- ការផ្គត់ផ្គង់វត្ថុធាតុដើម **កដត.** ផលិតផលសម្រេច ឬផលិតផលខូចខាត/លើស ទៅក្នុងទីផ្សារក្នុងស្រុកត្រូវជាប់អាករលើតម្លៃបន្ថែមតាមអត្រា ១០%

- ក្នុងករណីមានការកម្ទេចវត្ថុធាតុដើម **កជត.** ឬផលិតផលខូចខាត សហគ្រាសត្រូវជូនដំណឹងជាមុនដល់អគ្គនាយកដ្ឋានពន្ធដារ ដើម្បីរួចផុតពីកាតព្វកិច្ចអាករលើតម្លៃបន្ថែមតាមអត្រា ១០%។

**ខ- អាករលើធាតុចូល÷**

ឥណទានអាករលើធាតុចូលចំពោះអាករលើតម្លៃបន្ថែមដែលបានបង់លើទំនិញ ឬសេវាក្នុងស្រុកសម្រាប់សកម្មភាព **កជត.** ត្រូវអនុវត្តតាមមាត្រា២៩ ដល់មាត្រា៤១ នៃអនុក្រឹត្យលេខ១១៤ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីអាករលើតម្លៃបន្ថែម។

គ- សហគ្រាសដែលផ្គត់ផ្គង់សេវា **កជត.** ត្រូវអនុវត្តជាធម្មតានូវបទប្បញ្ញត្តិស្តីពីអាករលើតម្លៃបន្ថែម និងត្រូវកាន់ កត់ត្រាបញ្ជីគណនេយ្យអាករលើតម្លៃបន្ថែម ដូចមានចែងក្នុងមាត្រា ៥០ នៃអនុក្រឹត្យស្តីពីអាករលើតម្លៃបន្ថែម។

## ប្រការ ៨.- ការគ្រប់គ្រងសន្និធិ

សហគ្រាសដែលផ្គត់ផ្គង់សេវា **កជត.** ត្រូវកាន់ កត់ត្រា និងថែរក្សាកំណត់ត្រាគ្រប់គ្រងសន្និធិ ដែលអាចត្រួតពិនិត្យ និងតាមដានការប្រែប្រួលសន្និធិរបស់ម្ចាស់ទំនិញ។ កំណត់ត្រាគ្រប់គ្រងសន្និធិត្រូវមានព័ត៌មាន ដូចខាងក្រោម÷

១- សន្និធិវត្ថុធាតុដើម **កជត.**

ក- កំណត់ត្រាគ្រប់គ្រងសន្និធិដើម្បីតាមដានចលនានៃវត្ថុធាតុដើម **កជត.** របស់ម្ចាស់ទំនិញ រួមមាន÷

- បរិមាណវត្ថុធាតុដើមដែលបានទទួល
- បរិមាណវត្ថុធាតុដើមដែលចូលរួមក្នុងផលិតផលកំពុងផលិត
- បរិមាណវត្ថុធាតុដើមដែលខូចខាត
- បរិមាណវត្ថុធាតុដើមដែលបាននាំចេញទៅវិញ (ប្រសិនបើមាន)។

ខ- កំណត់ត្រាគ្រប់គ្រងសន្និធិដូចមានបញ្ជាក់ក្នុងវាក្យខណ្ឌ ក ខាងលើ ត្រូវមានឯកសារគាំទ្រដូចខាងក្រោម÷

- លិខិតទទួលទំនិញ ដែលមានកត់ត្រាបរិមាណ ឬសេចក្តីបរិយាយលម្អិតពីវត្ថុធាតុដើម **កជត.** ដែលបានទទួល
- លិខិតប្រគល់ទទួលទំនិញ សម្រាប់គាំទ្រលិខិតទទួលទំនិញ
- លិខិតបដិសេធគុណភាពវត្ថុធាតុដើម សម្រាប់កត់ត្រាបរិមាណវត្ថុធាតុដើមដែលខុសស្តង់ដា ឬខូចគុណភាព នឹងត្រូវបញ្ជូនទៅវិញ ក្នុងករណីបើមានការបញ្ជូនទៅវិញ
- ឯកសារសម្រាប់កត់ត្រាចលនាសន្និធិ ឬបរិមាណវត្ថុធាតុដើមដែលបញ្ចូលឃ្លាំង។

គ- សហគ្រាសដែលផ្គត់ផ្គង់សេវា **កជត.** ត្រូវបង្ហាញរាល់កំណត់ត្រាខាងលើនេះតាមការតម្រូវរបស់រដ្ឋបាលសារពើពន្ធ។

២- សន្និធិផលិតផលសម្រេច ត្រូវមានកំណត់ត្រាដូចខាងក្រោម÷

- សន្និធិដើមគ្រានៃផលិតផលសម្រេច
- បរិមាណផលិតផលសម្រេចផលិតបានក្នុងគ្រា

- សន្និធិចុងគ្រានៃផលិតផលសម្រេច។

៣- សន្និធិផលិតផល ដែលខូច ឬលើស (រួមបញ្ចូលវត្ថុធាតុដើម **កជត.** ប្រសិនបើមាន) ដែលត្រូវបញ្ជូនទៅកម្ទេច ឬបញ្ចេញចោល ត្រូវជូនដំណឹងជាមុនយ៉ាងតិច ០៧ (ប្រាំពីរ)ថ្ងៃ មកអគ្គនាយកដ្ឋានពន្ធដារ ដើម្បីចូលរួមត្រួតពិនិត្យការកម្ទេច ឬបញ្ចេញចោលនេះ។

សហគ្រាសដែលផ្គត់ផ្គង់សេវា **កជត.** ត្រូវផ្តល់របាយការណ៍ត្រួតពិនិត្យសន្និធិជារៀងរាល់ឆ្នាំជាមួយលិខិតប្រកាសពន្ធលើប្រាក់ចំណូល។

## ប្រការ ៩.- ការកាន់ កត់ត្រា និងការកែតម្រូវបញ្ជិកាគណនេយ្យ

១- សហគ្រាសដែលផ្គត់ផ្គង់សេវា **កជត.** ត្រូវកាន់ កត់ត្រា និងថែរក្សា បញ្ជិកាគណនេយ្យស្របតាមស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា និងបទប្បញ្ញត្តិស្តីពីសារពើពន្ធ។

២- ចំពោះសហគ្រាសដែលមានសកម្មភាពអាជីវកម្មផ្គត់ផ្គង់សេវា **កជត.** ផង និង មិនមែន **កជត.** ផង ត្រូវកត់ត្រាបញ្ចូលក្នុងរបាយការណ៍ហិរញ្ញវត្ថុរួម និងរៀបចំលិខិតប្រកាសពន្ធលើប្រាក់ចំណូលតែមួយ ប៉ុន្តែត្រូវមានឯកសារ និងកំណត់ត្រាគណនេយ្យ ដាច់ដោយឡែកពីគ្នា រវាងប្រតិបត្តិការ **កជត.** និង ប្រតិបត្តិការមិនមែន **កជត.**។

៣- ក្នុងករណីសហគ្រាសដែលផ្គត់ផ្គង់សេវា **កជត.** ដែលធ្វើការប្រកាសពន្ធកន្លងមកមិនបានឆ្លុះបញ្ចាំងពីប្រតិបត្តិការជាក់ស្តែង សហគ្រាសត្រូវធ្វើការកែតម្រូវលិខិតប្រកាសពន្ធលើប្រាក់ចំណូល ក្នុងរយៈពេល ០៣ (បី) ឆ្នាំថយក្រោយ។ លទ្ធផលនៃការកែតម្រូវដែលនាំឱ្យមានប្រាក់ពន្ធត្រូវបង់ត្រូវបានរួចផុតពីទោសទណ្ឌ ដែលក្នុងនោះមានពន្ធបន្ថែម និងការប្រាក់យឺតយ៉ាវ។ អាជ្ញាយុកាលនៃការកែតម្រូវ ត្រូវកំណត់ដោយសេចក្តីណែនាំរបស់អគ្គនាយកដ្ឋានពន្ធដារ។

៤- សហគ្រាសដែលផ្គត់ផ្គង់សេវា **កជត.** ត្រូវមានឯកសារគាំទ្រ ជាអាទិ៍÷

**ក. សម្រាប់ប្រតិបត្តិការលក់÷**

- កិច្ចសន្យាផ្គត់ផ្គង់សេវា **កជត.**
- វិក្កយបត្រលក់ (ការផ្គត់ផ្គង់សេវា ...)
- របាយការណ៍ធនាគារ
- ឯកសារទូទាត់ប្រាក់តាមធនាគារក្នុងស្រុក
- ប្រតិវេទន៍គយ និងឯកសារនាំចេញ
- លិខិតបញ្ជាក់ប្រភពដើមទំនិញ
- ឯកសារដឹកជញ្ជូន

**ខ. សម្រាប់ការនាំចូលវត្ថុធាតុដើម កជត.÷**

- លិខិតបញ្ជាបញ្ជូនទំនិញ
- វិក្កយបត្រសម្រាប់នាំចូល
- លិខិតប្រគល់ទទួលទំនិញ
- ប្រតិវេទន៍គយ និងឯកសារនាំចូល
- ឯកសារដឹកជញ្ជូន។

**ប្រការ ១០.-** **ការអនុវត្ត**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកឬអគ្គនាយក នៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធានអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងគ្រប់សហគ្រាសដែលពាក់ព័ន្ធ ត្រូវអនុវត្តតាមខ្លឹមសារ នៃប្រកាសនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ សុក្រ ៧រោច ខែទុតិយាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ សីហា ឆ្នាំ២០១៨

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី ខេត្ត
- ដូចប្រការ ១០ “ដើម្បីអនុវត្ត”
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឈ្មោះសហគ្រាស៖.............................. VATTIN: ............................ (តារាងឧបសម្ព័ន្ធ)

# តារាងលម្អិតអំពីថ្លៃឈ្នួលសេវាកម្ម កដត ប្រចាំខែ........ឆ្នាំ........

## Detail Cut Make and Trim Fee Table

### I. វិក្កយបត្រ (Invoice)

| វិក្កយបត្រ (Invoice) | | | | | ទឹកប្រាក់ Amount |
|---|---|---|---|---|---|
| ថ្ងៃទី Date | លេខវិក្កយបត្រ Invoice No | អ្នកទិញ Customer | បរិយាយ DESCRIPTION | បរិមាណ Quantity | |
| F1 | F2 | F3 | F4 | F5 | F6 |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | សរុប | | |

### II. សាច់ប្រាក់បានទទួល (Cash Receipt)

| ថ្ងៃទី Date | លេខសក្ខីបត្រ Voucher No | អ្នកទិញ Buyer | បរិយាយ DESCRIPTION | ទឹកប្រាក់ Amount |
|---|---|---|---|---|
| T1 | T2 | T3 | T4 | T5 |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | សរុប | |